31.8-10 35/6

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម

*សំណុំរឿងព្រហ្មទណ្ឌលេខ : ៣៧៨*
*ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១០*
*សាលក្រមលេខ : ៩២ "ង"*
*ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១០*

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកំពង់ចាម**

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះសាលាដំបូងខេត្តកំពង់ចាម នាថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១០ ដែលមានសមាសភាពជំនុំជំរះដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោកស្រី : [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ចាម

**តំណាងអយ្យការ**

លោក : [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម

**ក្រឡាបញ្ជីសវនាការ**

លោក : [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ចាម

**ដើម្បីជំនុំជំរះ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៨ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១០ ដែលមាន :

**ជនជាប់ចោទឈ្មោះ :**

១-[redacted] **ស្រ៊ន** ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ កើតនៅ [redacted] មុខរបរ កសិករ ប្រពន្ធឈ្មោះ [redacted] "រ" មានកូនពីរនាក់ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ទោសពីមុន គ្មាន ។

២-[redacted] **ស៊ាងលី** ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅ [redacted] មុខរបរ ធ្វើស្រែ ប្ដីឈ្មោះ [redacted] "រ" មានកូនពីរនាក់ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ទោសពីមុន គ្មាន ។

**ត្រូវជាប់ចោទពីបទ :បរិហារកេរ្តិ៍ និងជេរប្រមាថ** ប្រព្រឹត្តនៅភូមិរកាពយ "ខ" ឃុំរកាពយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៦៣ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** : [redacted] ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅ [redacted] មុខរបរ ធ្វើស្រែ ប្តីឈ្មោះ [redacted] (រស់លះ) ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** : [redacted] ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ មានទីលំនៅ [redacted] មុខរបរ ធ្វើស្រែ ប្តីឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ។

បានឃើញដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជំរះផ្ទាល់លេខ : ៩៩២ ព.ស ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០១០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ : ៧៨៤ព្រទ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ របស់អនុប្រធានសាលាដំបូងខេត្តកំពង់ចាម ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] **ស្រ៊ន** បានឆ្លើយថា : ថ្ងៃកើតហេតុខ្លួនមិននៅផ្ទះទេ ប្រពន្ធខ្លួនជាអ្នកឈ្លោះជាមួយភាគីម្ខាងទៀតឈ្មោះ ប៊ូរិន ផ្ទះជាប់របងគ្នា ពេលឈ្លោះគ្នានោះខ្លួនមិនដឹងទេ ពេលខ្លួនមកដល់ការឈ្លោះគ្នាបានចប់ទៅហើយ ។ ខ្លួន និងភាគីឈ្មោះ ប៊ូរិន មិនត្រូវរ៉ូវគ្នាទេ ដោយសារទាស់គ្នាតាំងពីចាស់ៗមកម្លេះ ។ ពេលឈ្លោះគ្នាខ្លួនមិនបាននៅកន្លែងកើតហេតុឡើយ ពេលមកដល់ផ្ទះប្រពន្ធប្រាប់ខ្លួនថា គេជេរខ្លួនថា អាតៃហោង ដោយខឹងខ្លួនបានដោតដើមផ្កាតាមព្រំដីកុំឱ្យគោចេញចូលក្នុងដី ម្យ៉ាងគេថាខ្លួនដោតចូលដីគេ ។ ខ្លួនមិនទទួលស្គាល់ការនិយាយរបស់សាក្សី និង ដើមបណ្តឹងទេ ព្រោះសាក្សីសុទ្ធតែស្និទ្ធបងប្អូន ខ្លួនគ្មានសាក្សីទេ ។

- ជនជាប់ចោទឈ្មោះ [redacted] **ស៊ាងលី** បានឆ្លើយថា : ខ្លួនបានដោតដើមផ្កាតាមព្រំដីមែន តែមិនបានចូលដីខាងគេទេ ដើម្បីកុំឱ្យគោគេចូលក្នុងដីខ្លួន ហើយភាគីឈ្មោះ ប៊ូរិន បានដកដើមផ្កានេះចោល ។ ក្រោយមកបានប្រកែកគ្នាជាមួយខ្លួន ខ្លួនក៏ជេរទៅ ហើយវាក៏ជេរមកខ្លួនវិញថា មីតៃហោង ចាំមើលអញសំលាប់ឯងអស់មួយពូជ គឺ ប៊ូរិន ជាអ្នកជេរទាំងប្អូនថ្លៃ និងប្រពន្ធ ។ ខ្លួនបានកាប់ដើមផ្ការំយោលដែលដាំតាមព្រំដីមែន ហើយភាគី ប៊ូរិន បានដកផ្កាខ្លួនដាំ ក៏មានការប្រកែកគ្នាចុះឡើងៗ ប៊ូរិន ជេរខ្លួន ចំណែកប្តីខ្លួនមិននៅផ្ទះទេ នៅផ្ទះឈ្មោះ ង៉ុយ ចំងាយពីផ្ទះខ្លួនជិតមួយគីឡូម៉ែត្រ ។ ខ្លួនមិនបាននិយាយបរិហារកេរ្តិ៍ដល់ដើមបណ្តឹងទេ ហើយខ្លួនក៏មិនបានឮសូរឈ្មោះ ប៊ូរិន ឈ្លោះជាមួយប្រពន្ធដែរ ខ្លួនមិនបាននិយាយពីដើមចោទថា យកប្តីគេទេ ។ ខ្លួនមិនទទួលស្គាល់ការនិយាយរបស់សាក្សី និងដើមបណ្តឹងជាការពិតទេ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយឱ្យការណ៍ថា : ដំបូងខ្លួននៅលើផ្ទះស្រាប់តែឮសូរ ស៊ាងលី ស្រែកជេរប្តីខ្លួន ខ្លួនក៏ចុះមកដីមើល ស្រាប់តែពេលឃើញខ្លួនជេរខ្លួនថា មីយកប្តីគេការបាន ០៦ខែ កើតកូន ខ្លួនមិនបានជេរតបទេ ព្រោះខ្មាស់គេក៏ចូលក្នុងផ្ទះវិញទៅ ។ ដោយសារតែពាក្យនិយាយបរិហាររបស់ឈ្មោះ ស៊ាងលី ធ្វើឱ្យខ្លួន និងប្តីឈ្លោះគ្នាស្ទើររាល់ថ្ងៃ រហូតដល់លែងលះគ្នា តែក្រោយមកបានចាស់ៗសំរុះសំរួលក៏ត្រូវគ្នាវិញ ។ ដំបូងឈ្មោះ ស្រ៊ន មិននៅកន្លែងកើតហេតុទេ បន្តិចក្រោយមកក៏ឃើញឈ្មោះ ស្រ៊ន មកដល់ ហើយក៏ជេរម៉ែខ្លួនឈ្មោះ [redacted] សុភាព នូវពាក្យអាក្រក់ៗ តែមិនបានជេរជាមួយខ្លួនទេ ។ ឈ្មោះ ស្រ៊ន ជេរម្តាយខ្លួនថា មីចោចមីសដាក់ក្បាលពេ មីចោរគេចុយ ។ ពេលឈ្លោះគ្នាមិនបានវាយតប់គ្នាទេ ។ ក្នុងពេលនេះខ្លួនសុំទាមទារជម្ងឺចិត្តចំនួន ១០,០០០,០០០ (ដប់លាន) រៀល ។



Scanned by CamScanner

- សាក្សីឈ្មោះ [redacted] **បូរិន** បានឆ្លើយបំភ្លឺថា : ខ្លួនមិនបានជេរតបទៅភាគីម្ខាងទៀតវិញទេ ។ ថ្ងៃកើតហេតុខ្លួនឃើញមេកតរដាំចូលព្រំដីខ្លួន ខ្លួនក៏ដក ហើយដោតចំពាក់កណ្ដាលព្រំដី ស្រាប់តែភាគី ស៊ាងលី ថាខ្លួនដកដើមតររបស់គេ ប្រកែកគ្នាចុះឡើងៗ ស្រាប់តែ ស៊ាងលី ស្រែកជេរខ្លួន និងប្រពន្ធខ្លួន ដោយជេរថា មីយកប្ដីគេ ការបាន ០៦ខែ កើតកូន ។ បន្តិចក្រោយមក ស្រ៊ន មកដល់ក៏ជេរម្ដាយខ្លួនថា មីចោរគេចុយ មីដកមមីសដាក់លើក្បាលគេ ។

- សាក្សីឈ្មោះ **ហ៊ឹ ស្រ៊ុង** បានឆ្លើយបំភ្លឺថា : ខ្លួនជាប់សាច់ញាតិឆ្ងាយជាមួយដើមចោទ នៅថ្ងៃកើតហេតុខ្លួននៅទីនោះដែរ ផ្ទះទល់មុខគ្នា ។ ដំបូងឮសូរឈ្លោះប្រកែកគ្នា ខ្លួនក្រោកឡើង ខ្លួនឃើញភាគីទាំងសងខាងឈ្លោះគ្នាពីរឿងព្រំដី ។ ដំបូងភាគីជនជាប់ចោទជេរទៅលើភាគីដើមបណ្ដឹងមុនគឺ ស៊ាងលី ជេរ ទៅលើប្រពន្ធ បូរិន ថា មីចោរកាចុយ មីចោរអាយះ និងនិយាយថា មីយកប្ដីគេការបាន ០៦ខែ កើតកូន ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយឱ្យការណ៍ថា : ដំបូងភាគីម្ខាងទៀតជេរមកខ្លួន និងកូនខ្លួន ចំណែកកូនខ្លួនមិនបានជេរគេទេ ។ ប្រពន្ធជេរកូនខ្លួន ឯប្ដីវាជេរខ្លួន ឥឡូវខ្លួនទារជំងឺចិត្តចំនួន ៥ប៉ុលានរៀល ។

- សាក្សីឈ្មោះ **អែម ចាន់នី** បានឆ្លើយបំភ្លឺថា : ផ្ទះខ្លួននៅខាងលិច តែនៅថ្ងៃកើតហេតុខ្លួននៅទីនោះគឺនៅផ្ទះឈ្មោះ លីម ។ ដំបូងប្រពន្ធ និងប្រពន្ធឈ្លោះ និងជេរគ្នាដោយ ស៊ាងលី ជេរទៅលើ រ៉ានី ថា មីចោរយកប្ដីគេ ការបាន ០៦ខែ កើតកូន ។

- សាក្សីឈ្មោះ **អ៊ាង សុភាព** បានឆ្លើយបំភ្លឺថា : ពេលកើតហេតុខ្លួនមិននៅទេ តែក្រោយមកខ្លួនជិះម៉ូតូទៅកាន់កន្លែងកើតហេតុក៏ឃើញ ស៊ាងលី និង រ៉ានី ឈ្លោះគ្នាដោយ ស៊ាងលី ជេរ រ៉ានី ថា មីយកប្ដីគេ ការបាន ០៦ខែ កើតកូន ។ ពេលនោះខ្លួនចូលទៅផ្ទះ រ៉ានី ដើម្បីយកក្រដាស់បង់ភ្លើង ពេលខ្លួនរៀបចេញមកវិញ ស្រាប់តែឈ្មោះ ស្រ៊ន ស្រែកជេរទៅឈ្មោះ [redacted] សុភាព ថា មីដកមមីសដាក់លើក្បាលគេ ។ នៅពេលដែលខ្លួនទៅផ្ទះ រ៉ានី គឺទៅជាមួយប្រពន្ធ ពេលនោះឈ្មោះ ស៊ាងលី បានជេរមកលើខ្លួន និងប្រពន្ធដែរ ព្រោះស្មានថាខ្លួនមកជួយភាគីខាង រ៉ានី ប៉ុន្តែខ្លួនមិនប្ដឹងឈ្មោះ ស្រ៊ន និងឈ្មោះ ស៊ាងលី ទេ ហើយខ្លួនមកនេះគឺគ្រាន់តែចង់និយាយបំភ្លឺតែប៉ុណ្ណោះ ។

- សាក្សីឈ្មោះ **ស៊ុម លីម** បានឆ្លើយបំភ្លឺថា : ថ្ងៃកើតហេតុខ្លួននៅក្រោមផ្ទះ ខ្លួនត្រូវជាបងប្អូនជាមួយភាគីទាំងពីរ ចំពោះនេះខ្លួនឮ ស្រ៊ន ជេរទៅ សុភាព ថា មីដកមមីសដាក់លើក្បាលគេ ។

- **តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា** : ក្រោយពីបានស្ដាប់ចំលើយជនជាប់ចោទទាំងពីរថា ខ្លួនមិនបានជេរទៅលើដើមបណ្ដឹងទេ ប៉ុន្តែដើមបណ្ដឹង និងសាក្សីបានឆ្លើយដូចគ្នាថា ជនជាប់ចោទឈ្មោះ [redacted] ស្រ៊ន និងប្រពន្ធឈ្មោះ [redacted] ស៊ាងលី ពិតជាបានជេរទៅដើមបណ្ដឹងមែន គឺ ស្រ៊ន ជេរទៅលើ [redacted] សុភាព រីឯ [redacted] ស៊ាងលី បានជេរទៅ [redacted] រ៉ានី ថា មីចោរយកប្ដីគេ ការបាន ០៦ខែ កើតកូន ។ ដូច្នេះតំណាងអយ្យការ សម្រេចចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីរខាងលើ បើយេសម្រេចតំកល់លិខិតចោទប្រកាន់លេខ : ៩៩២ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០១០ ទុកជាបានការតាមផ្លូវច្បាប់ ។

- **សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ** [redacted] **ស្រ៊ន ឆ្លើយថា** : គ្មានសំណូមពរអ្វីទេ ។

- **សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ** [redacted] **ស៊ាងលី ឆ្លើយថា** : សុំឱ្យតុលាការសម្រេចតាមច្បាប់ចុះ ។

ក្រោយពីបានស្ដាប់ចំលើយដោះសាររបស់ជនជាប់ចោទ

ក្រោយពីបានស្ដាប់ចំលើយឱ្យការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់ចម្លើយបំភ្លឺរបស់សាក្សី



Scanned by CamScanner

ក្រោយពីបានស្តាប់ការសួរដេញដោល

ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានាដែលមានក្នុងសំណុំរឿង

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការ យល់ឃើញថា :**

-តាមដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជំរះផ្ទាល់របស់តំណាងអយ្យការ ឃើញថា : កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៩ វេលាម៉ោងបីរសៀល នៅភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម មានអំពើល្មើស ជេរប្រមាថ និងបរិហារកេរ្តិ៍ កើតឡើងពិតប្រាកដមែន ។

-អំពើល្មើសដែលកើតឡើងនៅទីកន្លែង និងពេលវេលាខាងលើ ពិតជាបង្កឡើងដោយជនជាប់ចោទ ឈ្មោះ [redacted] ស្រ៊ន ភេទប្រុស អាយុ ៤៣ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] ស៊ាងលី ភេទស្រី អាយុ ៣៨ឆ្នាំ ប្រាកដមែន ដោយអ្នកទាំងពីរនាក់នេះបានប្រកែកគ្នាជាមួយឈ្មោះ [redacted] ប៊ុរិន អំពីរឿងព្រំដី ហើយក៏ជេរប្រមាថទៅលើឈ្មោះ [redacted] ប៊ុរិន . ឈ្មោះ [redacted] សុភាព ជាម្តាយក្មេក និងជេរបរិហាកេរ្តិ៍ទៅលើឈ្មោះ [redacted] រ៉ានី ជាប្រពន្ធរបស់ឈ្មោះ [redacted] ប៊ុរិន ទៀតផង ។

**ភស្តុតាងដាក់បន្ទុកមាន :**

- ចំលើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ាងលី បានឆ្លើយថា : ពិតជាមានការឈ្លោះប្រកែក និងជេរគ្នាទៅវិញទៅមកមែន ។
- ចំលើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឱ្យដឹងថា : ឈ្មោះ [redacted] ស៊ាងលី បានជេរមកលើខ្លួននូវពាក្យអាក្រក់ជាច្រើន ពិសេសបាននិយាយបរិហារថា "មីយកប្តីគេ ការបាន ០៦ខែ កើតកូន" ដោយសារសំដីនេះធ្វើឱ្យខ្លួន និងប្តីបានឈ្លោះគ្នាស្ទើររាល់ថ្ងៃរហូតដល់លែងលះគ្នា ឯខ្លួនមិនបានជេរទៅគេវិញទេ ព្រោះត្រូវគេជេរ ដូចនេះខ្មាសគេក៏ចូលទៅក្នុងផ្ទះវិញទៅ ។ ចំណែកឈ្មោះ [redacted] ស្រ៊ន បានជេរប្រមាថទៅលើម្តាយខ្លួននូវពាក្យអាសអាភាសអាក្រក់ៗ ។
- ចំលើយរបស់ដើមបណ្តឹងឈ្មោះ [redacted] បានឱ្យដឹងថា : ខ្លួនឮឈ្មោះ [redacted] ស៊ាងលី និងកូនខ្លួនឈ្មោះ [redacted] ប៊ុរិន ប្រកែកគ្នា ហើយឈ្មោះ [redacted] ស៊ាងលី ជេរមកលើកូនខ្លួន ខ្លួនក៏ចេញទៅមើល ស្រាប់តែប្តីរបស់ឈ្មោះ [redacted] ស៊ាងលី គឺឈ្មោះ [redacted] ស្រ៊ន បានជេរមកលើខ្លួនថា : "មីកញ្ជ្រោយដកមមីស ដាក់លើក្បាលគេ" ។
- ចំលើយរបស់សាក្សីឈ្មោះ [redacted] ប៊ុរិន បានបំភ្លឺថា : ខ្លួនឃើញមែកគរដាំខុសកន្លែង ខ្លួនក៏ដកទៅដាំកន្លែងដើមវិញ ស្រាប់តែឈ្មោះ [redacted] ស៊ាងលី ថាដាំចូលដីគេ ខ្លួនក៏ប្រកែកថា មិនបានដាំចូល ឈ្មោះ [redacted] ស៊ាងលី ក៏ជេរប្រមាថមកលើខ្លួន ប្រពន្ធខ្លួន និងម្តាយក្មេកខ្លួនក៏ចេញ ក៏ត្រូវឈ្មោះ [redacted] ស៊ាងលី និងប្តីជេរប្រមាថ និងបរិហារកេរ្តិ៍ ដូចជា" មីដកមមីសដាក់លើក្បាលគេ " និងថាប្រពន្ធខ្លួនយកប្តីគេ ការបាន ០៦ខែ កើតកូន ។
- សាក្សីឈ្មោះ ស៊ុម លឹម . ឈ្មោះ វែម ចាន់ទី និងឈ្មោះ ហ៊ី ស្រុង ដែលនៅកន្លែងកើតហេតុបានបំភ្លឺដូចគ្នាថា : ពួឈ្មោះ [redacted] ស៊ាងលី និងឈ្មោះ [redacted] ប៊ុរិន ប្រកែកគ្នារឿងព្រំដី បន្ទាប់មកឈ្មោះ [redacted] ស៊ាងលី និងប្តី



413

Scanned by CamScanner

ឈ្មោះ [redacted] ស្រ៊ន បានជេរប្រមាថទៅលើឈ្មោះ [redacted] បូរិន . [redacted] សុភាព និងថាឈ្មោះ [redacted] រ៉ានី យកប្ដីគេ ការបាន ០៦ ខែកើតកូន ។

- សាក្សីឈ្មោះ អ៊ាង សុភាព បានបំភ្លឺថា : ខ្លួន និងប្រពន្ធទៅយកសំបុត្របង់ថ្លៃភ្លើងពីផ្ទះ [redacted] រ៉ានី ឃើញឈ្មោះ ស្រ៊ន និងឈ្មោះ ស៊ាងលី កំពុងជេរឈ្មោះ បូរិន . ឈ្មោះ សុភាព និង រ៉ានី ។ ពេលនោះឈ្មោះ ស៊ាងលី បានជេរមកលើប្រពន្ធខ្លួនដែរ ព្រោះគេស្មានតែខ្លួន និងប្រពន្ធមកជួយខាងក្រុមគ្រួសារ រ៉ានី តែតាមពិតខ្លួនមកយកសំបុត្របង់ថ្លៃភ្លើងពីឈ្មោះ រ៉ានី ។

ហេតុនេះតាមចំលើយរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី គឺមានលក្ខណៈស៊ីសង្វាក់គ្នា ដែលបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ស្រ៊ន និងឈ្មោះ [redacted] ស៊ាងលី ពិតជាបានជេរប្រមាថទៅលើឈ្មោះ [redacted] បូរិន និងបរិហារកេរ្តិ៍ឈ្មោះ [redacted] រ៉ានី ថា យកប្ដីគេ ការបាន ០៦ខែ កើតកូនមែន ។ ឯការឆ្លើយរបស់ឈ្មោះ [redacted] ស្រ៊ន និងឈ្មោះ វ៉ន់ ស៊ាងលី ដែលថាមិនបានជេរប្រមាថ និងបរិហារកេរ្តិ៍ នោះគ្រាន់តែជាការឆ្លើយដោះសារគ្មានសំអាង មិនអាចឱ្យតុលាការយកមកពិចារណាបានឡើយ ។

-អំពើដែលជនជាប់ចោទឈ្មោះ [redacted] ស្រ៊ន និងប្រពន្ធឈ្មោះ [redacted] ស៊ាងលី ដែលបានជេរប្រមាថ និងបរិហារកេរ្តិ៍ទៅលើឈ្មោះ [redacted] សុភាព និងប្ដីប្រពន្ធឈ្មោះ [redacted] បូរិន-[redacted] រ៉ានី ធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ពិសេសគឺកិត្តិយស និងសេចក្ដីថ្លៃថ្នូរបុគ្គល ដែលច្បាប់ការពារ ។

-ជនជាប់ចោទឈ្មោះ [redacted] ស្រ៊ន និងឈ្មោះ [redacted] ស៊ាងលី ជាទីតិជន មានសតិស្មារតីល្អជាអាចពិចារណាពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន ។

-សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវ គប្បីតុលាការលើកមកពិចារណា និង សម្រេច ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស្រ៊ន និងឈ្មោះ [redacted] ស៊ាងលី ពីបទ ជេរប្រមាថ និងបរិហារកេរ្តិ៍ ប្រព្រឹត្តនៅភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៩ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៦៣ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

-ដើមបណ្ដឹងឈ្មោះ [redacted] បានប្ដឹងទាមទារជម្ងឺចិត្តចំនួន ១០.០០០.០០០ (ដប់លាន) រៀល ឯដើមបណ្ដឹងឈ្មោះ [redacted] ក៏បានទាមទារជម្ងឺចិត្តចំនួន ១០.០០០.០០០ (ដប់លាន) រៀលដែរ ពីជនជាប់ចោទទាំងពីរនាក់ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដូចនេះគប្បីតុលាការលើកមកពិចារណា និងសម្រេច ។

## ហេតុដូច្នេះ តុលាការ

## វិនិច្ឆ័យសេចក្ដី

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ :

ក. [redacted] **ស្រ៊ន** ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ខ. [redacted] **ស៊ាងលី** ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ១.០០០.០០០ (មួយលាន) រៀល ពីបទ ជេរប្រមាថ និងបរិហារកេរ្តិ៍ ប្រព្រឹត្តនៅភូមិរការគយ "ខ" ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៩



Scanned by CamScanner

តាមមាត្រា ៦៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ស្រ៊ន និងឈ្មោះ [redacted] ស៊ាងលី រួមគ្នាសងសំណងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ២.៥០០.០០០ (ពីរលានប្រាំសែន) រៀល និងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ។ ការទាមទារលើសពីនេះបដិសេធចោល ។

៣-សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រ៊ន-ឈ្មោះ [redacted] ស៊ាងលី និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឈ្មោះ [redacted] ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមជំនុំជំរះ |
| --- | --- |
| ហត្ថលេខា និងត្រា : [redacted] | ហត្ថលេខា និងត្រា : [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពង់ចាម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០

ក្រឡាបញ្ជី

[redacted]

ឃើញ

ចៅក្រមជំនុំជំរះ

[redacted]





Scanned by CamScanner